# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-៩-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/២៨៧ ស្តីពីការលើកលែងទោសឱ្យទណ្ឌិត ២ រូប : *១- កែន សាភ . ២- ផន រ៉ាសនា* ៣១២៧


## II-ក្រុមប្រឹក្សាធម្មនុញ្ញ


១៨-៩-២០០៣ -លិខិតលេខ ១៩/២០០៣ កបធ ស្តីពីការយាង**ព្រះករុណាសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**ទៅបើករដ្ឋសភានៃនីតិកាលទី ៣ ៣១២៨


## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៣-៩-២០០៣ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣១២៩

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការកំណត់ចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក សំរាប់ការចូលរៀនដោយសមធមិនៅមធ្យមសិក្សាបឋមភូមិ ៣១៣១

១៧-៩-២០០៣ -អនុក្រឹត្យលេខ ៨៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៣៣

១៧-៩-២០០៣ -អនុក្រឹត្យលេខ ៨៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៣៤

១៧-៩-២០០៣ -អនុក្រឹត្យលេខ ៨៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៣៥

១៨-៩-២០០៣ -អនុក្រឹត្យលេខ ៨៤១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣១៣៧

១៩-៩-២០០៣ -អនុក្រឹត្យលេខ ៨៤២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣១៣៨

១៩-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៣៩

២២-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤០

២២-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិកពេញសិទ្ធ នៃរាជបណ្ឌិតសភាកម្ពុជា ៣១៤១

២២-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤២

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤៣

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣១៤៥

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៨៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤៦

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៨៥០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣១៤៧

២៣-៩-២០០៣ -អនុក្រឹត្យលេខ ៨៥១ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល អោយមកបំរើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៣១៤៨
២៩-៩-២០០៣ -អនុក្រឹត្យលេខ ៨៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤៩
២៩-៩-២០០៣ -អនុក្រឹត្យលេខ ៨៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៥០
២៩-៩-២០០៣ -អនុក្រឹត្យលេខ ៨៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៥១
៣០-៩-២០០៣ -អនុក្រឹត្យលេខ ៨៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៥២

## ២-សេចក្តីសំរេច

១៦-៩-២០០៣ -សេចក្តីសំរេចលេខ ៦៣ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការសិក្សា និងវាយតម្លៃលើការសុំបូមស្តារ ព្រែកកោះប៉ោ និងមាត់ព្រែកពាមក្រសោប របស់ខេត្តកោះកុង ៣១៥៣
១៨-៩-២០០៣ -សេចក្តីសំរេចលេខ ៦៤ សសរ ស្តីពីការបង្កើតគណៈកម្មការពិនិត្យវាយតម្លៃ និងជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់ផ្លូវជាតិលេខ ៥ និង ៦ (ប៉ោយប៉ែត-សៀមរាប) និងផ្លូវលេខ ៥៦ និង ៦៨ (ស៊ីសុផុន-សំរោង-ក្រឡាញ់) ៣១៥៥

## IV-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-៩-២០០៣ -ប្រកាសលេខ ២៦៨ MOC/M 2003 ស្តីពីលទ្ធផល នៃការដេញថ្លៃកូតាសំរាប់នាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៣ ៣១៥៧

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

៣០-៩-២០០៣ -ប្រកាសលេខ ៩២០ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ " ត្បែងមានជ័យ " ទៅជាវិទ្យាល័យ " ជា ស៊ីម ត្បែងមានជ័យ " ស្ថិតនៅក្នុងឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ៣១៦១
៣០-៩-២០០៣ -ប្រកាសលេខ ៩២១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ វ៉ារិន ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប ៣១៦២
៣០-៩-២០០៣ -ប្រកាសលេខ ៩២២ អយក.ប្រក ស្តីពីការ បើកអនុវិទ្យាល័យ ចុងឃ្នៀស ស្ថិតនៅក្នុងឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប ៣១៦៣

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២៣-៩-២០០៣ -សេចក្តីសំរេចលេខ ៣៤២ ក.ធ.ស សរ ស្តីពីការឯកភាពលើការតែងតាំង គណៈកម្មការសង្ឃសាសនា មហាយាន (វៀតណាម) ៣១៦៤

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៣/២៨៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និង បន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលើកលែងទោសអោយទណ្ឌិត ២ រូប ដែលត្រូវផ្តន្ទាទោសតាមអំណាចសាលក្រមលេខ ៦១" ង" ចុះថ្ងៃទី ០២-១៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញ ហើយមានរាយនាមដូចខាងក្រោម ÷

១- ទណ្ឌិតឈ្មោះ កែន សារ៉ា ភេទ ប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ហើយត្រូវតុលាការដាក់ពន្ធនាគាររយៈពេល ៩ ខែ ពីបទញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋបានសំរេចផល ញុះញង់អោយមានការរើសអើង និងធ្វើបាតុកម្មគ្មានច្បាប់អនុញ្ញាត និងធ្វើបាតុកម្មឆ្លៀតឱកាសប្រើអំពើហឹង្សា យោងតាមមាត្រា ៥៩.៦១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងតាមមាត្រា ៦.៩ នៃច្បាប់ស្តីពីបាតុកម្ម ។

២- ទណ្ឌិតឈ្មោះ ថន វាសនា ភេទ ប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ហើយត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៨ ខែ ពីបទញុះញង់អោយមានការរើសអើងតាមមាត្រា ៦១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ២ ៣៧៦ ល

ជូនដើម្បីចម្លងចែក

ពរល.០៣.០៩.២៩៨

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣

ឧណាខី តាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣

លេខ 19/2003 កបធ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាសម្តេចព្រះនរោត្តម សីហនុ**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**កម្មវត្ថុ** : ការយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣

**យោង** : ព្រះរាជសារ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣

ទូលព្រះបង្គំយើងខ្ញុំ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ហើយបានសម្រេចជាឯកច្ឆ័ន្ទថា តាមមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រត្រូវកោះប្រជុំបើកសម័យប្រជុំដំបូងរដ្ឋសភា ៦០ ថ្ងៃ យ៉ាងយូរ ក្រោយពេលបោះឆ្នោត ។ ព្រះរាជវត្តមាននៃព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ក្នុងការបើកសម័យប្រជុំដំបូងមានសារសំខាន់ណាស់ចំពោះប្រជាជាតិទាំងមូល និង ចំពោះស្ថាប័នដ៏កំពូលនេះ ។ ជាទម្លាប់កន្លងមកព្រះករុណាតែងតែទ្រង់បានផ្តល់កិត្តិយស ដោយព្រះអង្គទ្រង់បានយាងទៅជាព្រះរាជអធិបតីនៃពិធីបើកសម័យប្រជុំដំបូងរបស់រដ្ឋសភា ។

អាស្រ័យហេតុនេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះរាជានុញ្ញាតថ្វាយយោបល់ថា ព្រះករុណាត្រូវយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣ នេះ ។

សូមក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១. ចុះថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤៧ លានរៀល ( សែសិបប្រាំពីរលានរៀលគត់ )ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារ: និង ការផ្គត់ផ្គង់តូច ) មកជំពូក ៣១ ( អន្តរាគមន៍ក្នុង វិស័យសង្គមកិច្ច និង វប្បធម៌ ) របស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ឧបត្ថម្ភដល់អ្នកសុំឈប់បំរើពីការងារ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកំណត់ចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក សំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ

*****

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ-បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកំណត់ចំណាយដោយឡែក សំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និង កីឡា

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣

## សំរេច

### មាត្រា ១.-

អនុក្រឹត្យនេះកំណត់ការចំណាយដោយឡែកសំរាប់ការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅកំរិតមធ្យមសិក្សាបឋមភូមិ ដែលប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា តែប៉ុណ្ណោះ ។

**មាត្រា ២.-**

ការចំណាយដោយឡែកនេះ ត្រូវអនុវត្តសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ រៀងរាល់ឆ្នាំ ចាប់ពី ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣ តទៅ ។

**មាត្រា ៣.-**

ប្រាក់ឧបត្ថម្ភផ្តល់ដល់សិស្សអាហារូបករណ៍ក្រោមកម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ជូនយ៉ាងច្រើន ១៨០.០០០៛ ( មួយរយប៉ែតសិបពាន់រៀលគត់ ) ក្នុងមួយនាក់ ក្នុងឆ្នាំសិក្សានីមួយៗ ដែលមាន ១០ (ដប់)ខែ សំរាប់ការផ្គត់ផ្គង់សំភារៈសិក្សាជាមូលដ្ឋាន សំលៀកបំពាក់ឯកសណ្ឋាន និង មធ្យោបាយធ្វើដំណើរ ។

ការផ្តល់អាហារូបករណ៍ក្នុងឆ្នាំសិក្សានីមួយៗមានចំនួន ៣ (បី)លើក ស្របតាមឆ្នាំថវិកា ។

**មាត្រា ៤.-**

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវធ្វើសារាចរណែនាំ ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ ក្នុងការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៥
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៩៧៨...អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៥ គ្រឿង ជូនសប្បុរសជន ចំនួន ០៥រូប ដែល បានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងម៉ាស្ជិត (វិហារឥស្លាម) នៅភូមិស្វាយបាការទូលពង្រ ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-លោកហាជ្ជី **យ៉ា ជាក់ហ្វឹត** ថវិកា ១៥.៥០០ ដុល្លារ

២-លោកបណ្ឌិត **ហាសាន់ ម៉ាស្រី** ថវិកា ១២.០០០ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

-លោកហាជ្ជី **យ៉ា ហារូន** ថវិកា ៨.៥០០ ដុល្លារ

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោកហាជ្ជី **ហ៊ីម អ៊ីសា** ថវិកា ៤.០០០ ដុល្លារ

២-លោក **លី ម៉ាន** ថវិកា ៣.៨៣០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤៣៩...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៦គ្រឿង ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងវត្តទន្លាប់ និង អគារសិក្សា ចំនួន០២ខ្នង នៅក្នុងសាលាបឋមសិក្សាទន្លាប់ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក **សោ ម៉ុច** | និង អ្នកស្រី **អាំ បូផល** | ថវិកា | ១០.០០០ ដុល្លារ |
| ២-លោក **សោ ស៊ីន** | និង អ្នកស្រី **លីម សុខុម** | ថវិកា | ១០.០០០ ដុល្លារ |
| ៣-លោក **ចៅ កាត់ឃិញ** | និង អ្នកស្រី **ចាន់ គិតហ្វុង** | ថវិកា | ១០.០០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| -លោក **អ៊ុន ជីតាន់** | និង អ្នកស្រី **ចៅ ឡូហ្វាន់** | ថវិកា | ៧.៩៣០ ដុល្លារ |

**គ_មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកវេជ្ជបណ្ឌិត **តាន់ ឆោ** | និង អ្នកស្រី **សោ នន្ទា** | ថវិកា | ៤.០០០ ដុល្លារ |
| ២-លោក **មាស ម៉ាន់ស៊ី** | និង អ្នកស្រី **សោ ជេតុណា** | ថវិកា | ៣.៨០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
114 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

**សំរេច**

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១២គ្រឿង ប្រគេន និង ជូន សប្បុរសជនចំនួន ១២រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមចំណែកក្នុងការ កសាងព្រះវិហារ អគារសិក្សា កុដិ ស្រះទឹក និង ក្លោងទ្វារ នៅក្នុងពុទ្ធសីមា វត្តឧត្តរវារី ភូមិកូនត្រី ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ កោសលមេធី **ណាន់ សុចិន្តា** ព្រះវិន័យធរខេត្តបន្ទាយមានជ័យ បច្ច័យ ១២.៥០០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ២-ព្រះគ្រូ | **ថា** | **ម៉ុនឡាត់** | ថវិកា ១១.៥០០ | ដុល្លារ |
| ៣-ព្រះគ្រូ | **ខ្មែម** | **សឿង** | ថវិកា ១១.៣២០ | ដុល្លារ |
| ៤-លោក | **គុំ** | **ហាច** | ថវិកា ១២.៥០០ | ដុល្លារ |
| ៥-លោក | **ទិឈាន** | **សែនគិត** | ថវិកា ១១.៨០០ | ដុល្លារ |
| ៦-លោក | **នូ** | **ខៀនមឿន** | ថវិកា ១០.៨៨០ | ដុល្លារ |
| ៧-លោក | **គុំថន** | **គួន** | ថវិកា ១០.៦៩០ | ដុល្លារ |
| ៨-លោក | **ថន** | **និនិត** | ថវិកា ១០.០០០ | ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| -លោក | **ឡុយ** | **ថនសៃ** | ថវិកា | ៥.៥៦០ ដុល្លារ |

**គ. មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ផែន** | **ខាំ** | ថវិកា | ៣.៥០០ ដុល្លារ |
| ២-លោក | **ធី** | **យន់** | ថវិកា | ៣.៣០០ ដុល្លារ |
| ៣-លោក | **ឱដាយ** | **ចំរើន** | ថវិកា | ៣.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៤៦...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអ្នកជំនាញការ ០២រូប នៃ គំរោងកម្ពុជា-អូស្ត្រាលី សំរាប់ការប្រឡង ថ្នាក់ជាតិ ( CANEP ) ដែលបានមកបំពេញបេសកកម្ម ជួយកែលំអគុណភាពបច្ចេកទេស និង ឧបត្ថម្ភសំភារៈ ដល់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ នៅព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ ២០០០ ដល់ ឆ្នាំ ២០០៣ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

១-លោក **Iann Kidd** ប្រធានគំរោង **CANEP**

២-លោក **Peter Leth** មន្ត្រីជំនាញកុំព្យូទ័រ នៃគំរោង **CANEP**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច

152 - ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៨៤៨...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សកលវិទ្យាធិការ នៃ សកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ស ំ រ េ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី **Monique Callamand** ភរិយាឯកអគ្គរដ្ឋទូត នៃ សាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការជួយបង្រៀននិស្សិត នៅដេប៉ាតឺម៉ង់ ភាសាបារាំង នៃ សកលវិទ្យាល័យ ភូមិន្ទ ភ្នំពេញ អស់រយៈពេល ០៤ឆ្នាំ ដោយស្ម័គ្រចិត្ត មិនទទួលបៀវត្ស ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា និងសកលវិទ្យាធិការ នៃ សកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ជួយកសាងផ្លូវចាក់បេតុងឡើងភ្នំ ប្រវែង ១៧៨ ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ស្ពានប្រឡាយ ទឹក និង ដីកជី លើកថ្មចាក់ផ្លូវលំ នៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ចំណាយ អស់ទឹកប្រាក់ សរុបចំនួន ៤៩.៥០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោកវរសេនីយ៍ទោ **គ្លន់ សារា** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ខេត្តបន្ទាយមានជ័យ

២-លោកស្រី **ស៊ឹម ទាន់** ភរិយា លោកវរសេនីយ៍ទោ **គ្លន់ សារា**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៧៤៤.អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូនលោកស្រី **ម៉ារី ក្លេប៉ូ** ( **MARIE CLAIPO** ) តំណាងអង្គការសហការប្រចាំកម្ពុជា (ICC) ដែលបានផ្ដល់ថវិកា សំរាប់ជួយកសាង និង អភិវឌ្ឍន៍ វិស័យសុខាភិបាល នៅខេត្តកំពង់ចាម តាំងពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០១ ចំណាយអស់ទឹកប្រាក់ សរុប ចំនួន ៨៥៣.៦៤០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

159

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ [illegible]

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០០ ស្តីពីបុព្វសិទ្ធិរបស់បុគ្គលិក និងសមាជិកនៃរាជបណ្ឌិតសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា១:** តែងតាំង ឯកឧត្តម បណ្ឌិតរដ្ឋ **គិច សំណាង** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **សៅ សុវណ្ណី** នាយកក្រុមហ៊ុនមុន្នីស៊ីណាម៉ិច ដែលបានឧបត្ថម្ភជាទឹកប្រាក់ចំនួន **១២០.០០០** ដុល្លារអាមេរិក ដើម្បីយកមកអភិវឌ្ឍន៍ និង ស្តារហេដ្ឋា - រចនាសម្ព័ន្ធ នៅក្នុងរាជធានីភ្នំពេញ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩៤៣...អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** គ្រប់លំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១៩រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យអប់រំ គមនាគមន៍ និង ព្រះពុទ្ធសាសនា នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះគ្រូ | **ឆេង** | **រាម** | គង់នៅវត្តស្វាយសាច់ភ្នំ ទឹកប្រាក់ចំនួន ៤.៩៥០ ដុល្លារ និង ៣៨.៤៥៨.០០០ រៀល ។ |
| ២-ព្រះភិក្ខុ | **លី** | **ម៉េងឃួង** | គង់នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ |
| ៣-ព្រះគ្រូ | **សាន់** | **សារេន** | គង់នៅវត្តចន្ទនារាម ទឹកប្រាក់ ចំនួន ១៨.៩៧៤ ដុល្លារ |
| ៤-ឯកឧត្តម | **ឈាង** | **ខុន** | ឯកអគ្គរាជទូតប្រចាំសាធារណរដ្ឋកូរ៉េ ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| -អ្នកស្រី | **ហា** | **រ៉ាន់** | នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ |

**គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសក | ខ្វិ | យ៉េម | នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.០០០ ដុល្លារ |
| ២-ឧបាសក | នេត | ឡេង | នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.២៤០ ដុល្លារ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣-ឧបាសក | ឈូ | ស្រ៊ី | នៅភូមិសាច់ភ្នំ | ទឹកប្រាក់ចំនួន | ២.៧៦៦ | ដុល្លារ |
| ៤-អ្នកស្រី | ម៉ូ | នីតា | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ២.២៧០ | ដុល្លារ |
| ៥-កញ្ញា | អេន | ម្លិះ | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.៥៥០ | ដុល្លារ |
| ៦-លោក | ម៉ុន | ស៊ឿន | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.៤៣០ | ដុល្លារ |
| ៧-លោក | អ៊ុំ | ចាន់ | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.០៥០ | ដុល្លារ |
| ៨-លោក | សុខ | ហេង | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.១៥០ | ដុល្លារ |
| ៩-លោក | សាមាន | សំ | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.១៤៥ | ដុល្លារ |
| ១០-លោកយាយ | អ៊ាត | សាមឿន | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ៤.៧៦៧ | ដុល្លារ |
| ១១-លោក | អ៊ុត | ស៊ឿន | នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន | ២.២០០ | ដុល្លារ |
| ១២-លោកយាយ | ម៉ក់ | នាង | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ២.២៣៧ | ដុល្លារ |
| ១៣-លោកយាយ | ចាន់ | ខឹន | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ២.០០០ | ដុល្លារ |
| ១៤-លោក | អ៊ុំ | សន្លាប់ | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.២៣០ | ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

166

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៨៤៨...អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ស ំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនជំនាញការជប៉ុន ចំនួន ០២រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការធ្វើសហប្រតិបត្តិការជួយដល់វិស័យសាធារណការ និង ដឹកជញ្ជូនកម្ពុជា ព្រមទាំងផ្ទេរចំណេះដឹងបច្ចេកទេស នៃការប្រើប្រាស់ និងជួសជុលគ្រឿងចក្រធំៗ ដល់មន្ត្រីរាជការកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១-លោក **MASARU KAWAMURA** ជំនាញការ **JICA** ប្រចាំក្រសួងសាធារណការ និង ដឹកជញ្ជូន

២-លោក **DAVID Y ONO** ជំនាញការ **JICA** ប្រចាំមជ្ឈមណ្ឌលគ្រឿងចក្រធំៗ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣

ទីស្តីការគណៈរដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

175

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥៤៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក OH IN-KYO អភិបាលខណ្ឌ ៣៥៤ នៃ សាធារណរដ្ឋកូរ៉េ និង ជានាយក Lions Club International ដែលបានផ្តល់អំណោយ ជាសម្ភារៈ និង ស្បៀងអាហារ សំរាប់ជួយឧបត្ថម្ភជីវភាព និង ជួយរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស ក្នុង កងយោធពលខេមរភូមិន្ទ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកង យោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៥០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក KIM JUNG WOOK អគ្គនាយកអង្គការពន្លឺសំរាប់ជីវិត (LAMP FOR MERCY) នៃសាធារណរដ្ឋកូរ៉េ ដែលមាន ស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការធ្វើសហប្រតិបត្តិការជួយឧបត្ថម្ភដល់ការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងកងយោធពលខេមរភូមិន្ទ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៥១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល អោយមកបំរើការងារ នៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ចំនួន ០២ នាក់ អោយមកបំរើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១- លោក **សុខ សារ៉េត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

២- លោក **សាន លុច** មន្ត្រីបំរើការងារនៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៣

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

## ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ព្រះវិហារ កុដិ ឧបដ្ឋានសាលា ផ្លូវលំ របង ក្លោងទ្វារ ស្ពាន និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងស្រុកកណ្ដៀង ខេត្តពោធិសាត់ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **នុត លាក់** ព្រះចៅអធិការវត្ត កញ្ជរខាងជើង បច្ច័យ ១៥.៣៥៨ ដុល្លារ

២-លោក **ជុំ គីមឌី** ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តពោធិសាត់ ថវិកា ១៤.៤០៩.២២ ដុល្លារ

៣-លោក **លឹម ចន្ទថៃ** ប្រធានរតនាគារ ខេត្តពោធិសាត់ ថវិកា ១០.៣០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិសាត់ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...[illegible]...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកក្នុងការកសាងអគារសិក្សា ព្រះវិហារ សាលាឆាន់ និង សមិទ្ធផលជាច្រើនទៀត ព្រមទាំងបានទិញសារ៉ុង ក្រមា សៀវភៅ ប៊ិច ឧបត្ថម្ភលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅក្នុងស្រុកភ្នំក្រវាញ ស្រុកកណ្តៀង និងស្រុកបាកាន ខេត្តពោធិសាត់ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ខ្វាន់ ស៊ាម** មេបញ្ជាការ បញ្ជាការដ្ឋានវិស្វកម្ម កងយោធពលខេមរភូមិន្ទ ថវិកា ១៤.៥០០ ដុល្លារ

២-ឯកឧត្តមបណ្ឌិត **ម៉ិច សុផាត** ទីប្រឹក្សា ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង លោកជំទាវ **ខួន ឃួរ** ថវិកា ១០.៧០០ ដុល្លារ

៣-ឯកឧត្តម **លី ធារុន** អគ្គនាយករង ក្រសួងបរិស្ថាន ថវិកា ១៣.០០០ ដុល្លារ

៤-ឯកឧត្តម **សែម សុវណ្ណនី** មេបញ្ជាការរងបញ្ជាការដ្ឋានវិស្វកម្ម កងយោធពលខេមរភូមិន្ទ ថវិកា ១៣.២០០ ដុល្លារ

៥-លោក **អ៊ុំ ម៉េងគី** និង លោកស្រី **អ៊ា ម៉េងហ៊ាង** សប្បុរសជនខ្មែរ នៅប្រទេសបារាំង ថវិកា ១០.៣០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៨៥៤...អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ំ រេ ច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៤គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារ វត្ត ពោធិព្រះពន្លា ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចបានរាយនាមខាងក្រោម ៖

**ក. មេដាយមាសស្ថាបនាជាតិ ៖**

១-លោក **ជា លីម៉េង** សប្បុរសជន នៅប្រទេសបារាំង ថវិកា ចំនួន ១២.២៥៦ USD

២-លោក **ចាន់ លីហេង** សប្បុរសជន នៅក្រុងភ្នំពេញ ថវិកា ចំនួន ១០.៧០១ USD

៣-លោក **ឯក សារិន** សប្បុរសជន នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១១.៤៣៣ USD

**ខ. មេដាយប្រាក់ស្ថាបនាជាតិ ៖**

-លោក **ខុន ស្រួច** សប្បុរសជន នៅចំការអណ្តូង ថវិកា ចំនួន ៧.៣២៦ USD

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំ រេ ច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូនលោក **KAM SANI** ប្រធានសមាគម **ODYSSEY** នៅប្រទេសសិង្ហបុរី ដែលបានជួយកសាងអគាររបេង មួយខ្នង ក្នុងមន្ទីរពេទ្យបង្អែក ពញាក្រែក ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ ចំនួន ១០.៥០០ ដុល្លារ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៦៣ សសរ.....

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការសិក្សា និងវាយតំលៃលើការសុំបូមស្តារ ព្រែកកោះប៉ោ និងមាត់ព្រែកពាមក្រសោប របស់ខេត្តកោះកុង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ .-**

បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការសិក្សា និងវាយតំលៃលើការសុំបូមស្តារព្រែកកោះប៉ោ និងមាត់ព្រែកពាមក្រសោប របស់ខេត្តកោះកុង ដែលមានសមាសភាពដូចខាង ក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **យុទ្ធ ភូថង** | អភិបាលខេត្តកោះកុង | ជាប្រធាន |
| ២-លោក | **សុខ ឡេង** | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាអនុប្រធាន |
| ៣-ឯកឧត្តម | **ទេង សាខុន** | តំណាងក្រសួងធនធានទឹកនិងឧតុនិយម | ជាអនុប្រធាន |
| ៤-លោក | **ស៊ុន គីមស្រ៊ុន** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-លោក | **អ៊ឹង ទ្រី** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |

៦-លោក **ឆាយ ថាន់ឆន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧-លោក **ខួន គង់** តំណាងក្រសួងបរិស្ថាន ជាសមាជិក

៨-លោក **ខៀវ អាន** តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

**ប្រការ ២ .-**

គណៈកម្មការខាងលើនេះ មានសិទ្ធិ និងភារកិច្ចដូចតទៅ ÷

-ធ្វើការសិក្សា និងវាយតំលៃ :

- បរិមាណទំហំដែលត្រូវដឹក
- ចំនួនភាគរយនៃដីល្បាប់ និងដីខ្សាច់ដែលលាយគ្នា
- ការរាំងស្ទះមុខទឹក
- ការចាក់សំណល់អាចម៍ដី
- វិភាគរ៉ែ ដែលនៅក្នុងដីដឹកចេញ
- ការវាយតំលៃ EIA
- ប៉ាន់ស្មានតំលៃដឹក ប្រៀបធៀបនឹងតំលៃលក់ខ្សាច់
- បច្ចេកទេសនៃការដឹក

-ត្រូវធ្វើរបាយការណ៍ អំពីសកម្មភាព និងលទ្ធផលការងាររបស់គណៈកម្មការ ប្រគល់មកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទីស្តីការគណៈរដ្ឋមន្ត្រីរៀបចំដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកោះកុង ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួនក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៤ . សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការពិនិត្យ វាយតម្លៃ និងជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់ផ្លូវជាតិលេខ ៥ និង ៦ (ប៉ោយប៉ែត-សៀមរាប) និងផ្លូវលេខ ៥៦ និង ៦៨ (ស៊ីសូផុន-សំរោង-ក្រឡាញ់)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់ និងជ្រើសរើសក្រុមហ៊ុនសាងសង់ផ្លូវជាតិលេខ ៥ និង ៦ (ប៉ោយប៉ែត-សៀមរាប) និងផ្លូវលេខ ៥៦ និង ៦៨ (ស៊ីសូផុន-សំរោង-ក្រឡាញ់) ក្រោមហិរញ្ញប្បទាន នៃឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម | **ឈិន គង់ហ៊ាន** | អគ្គនាយកសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-ឯកឧត្តម | **វង្សី វិស្សុត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក | **វ៉ា ស៊ីមសុរិយា** | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥-លោក | **រស់ បុរម** | អនុប្រធាននាយកដ្ឋាន វិនិយោគនិងសហប្រតិបត្តិការ សហវ. | សមាជិក |
| ៦-លោក | **ផែង សុទិដ្ឋារោ** | មន្ត្រីគំរោង ADB ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក | **ឃុន សុខា** | មន្ត្រី នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះ មានភារកិច្ចរៀបចំការកំណត់នូវគោលការណ៍ សំរាប់ពិនិត្យ វាយតំលៃ ដើម្បីធ្វើការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស និងក្រុមហ៊ុនសាងសង់ ប្រកបដោយភាពរលូន និងមានលក្ខណៈត្រឹមត្រូវ ដោយផ្អែកតាមគោលការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

**ប្រការ៣ :** ប្រធានគណៈកម្មការ មានសិទ្ធិកោះប្រជុំសមាជិករបស់ខ្លួន ដើម្បីពិភាក្សាលើបញ្ហាពាក់ព័ន្ធនានា ។ នាយកគំរោង មានភារកិច្ចធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី តាមការឯកភាពរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ២៦៤ MOC / M 2003

***From the Minister's Desk***

ភ្នំពេញ,ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៣

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះ តាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ២៦៥ MoC/M2003 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៣ ។
- យោងតាមការចាំបាច់នៃការងារ ។

## សម្រេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៣ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៣ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ីយ៉ា_សែម

ចំលងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

  " ដើម្បីជ្រាបជាពតិមាន"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ANNEX - A

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

10:02 AM, 09/18/2003

MINISTRY OF COMMERCE
TENDER of QUOTA

**TENDER of QUOTA**
**September 18, 2003**

| ID | COMPANY NAME | 334/634 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **18,763** | **$3.00** | | | |
| 1 | SOUTH BAY ENTERPRISE CO.,LTD | 11,000 | $4.60 | $50,600.00 | $5,060.00 | $45,540.00 |
| | TOTAL | 11,000 | | $50,600.00 | $5,060.00 | $45,540.00 |

| ID | COMPANY NAME | 338/339 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **250** | **$3.00** | | | |
| 1 | YOU CHENG GARMEENT CO.LTD | 250 | $3.20 | $800.00 | $80.00 | $720.00 |
| | TOTAL | 250 | | $800.00 | $80.00 | $720.00 |

| ID | COMPANY NAME | 340/640 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **260,413** | **$0.80** | | | |
| 1 | MSI GARMENT( CAMBODIA ) Ltd | 26,600 | $0.80 | $21,280.00 | $2,128.00 | $19,152.00 |
| 2 | ETERNAL WAY ( CAMBODIA) LTD | 23,000 | $0.80 | $18,400.00 | $1,840.00 | $16,560.00 |
| 3 | LUEN THAI GARMENT ( CAMBODIA) CO., LTD | 8,365 | $0.80 | $6,692.00 | $669.20 | $6,022.80 |
| | | **57,965** | | **$46,372.00** | **$4,637.20** | **$41,734.80** |

| ID | COMPANY NAME | 345 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **20,347** | **$1.00** | | | |
| 1 | M&V INTERNATIONAL MANUFACTURING | 420 | $3.00 | $1,260.00 | $126.00 | $1,134.00 |
| | | **420** | | **$1,260** | **$126** | **$1,134** |

| ID | COMPANY NAME | 347/348/647/648 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **696** | **$5.00** | | | |
| 1 | S.H INTERNATIONAL CO.,LTD | 696 | $13.00 | $9,048.00 | $904.80 | $8,143.20 |
| | TOTAL | 696 | | $9,048.00 | $904.80 | $8,143.20 |

| ID | COMPANY NAME | 352/652 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **43,317** | **$0.60** | | | |
| 1 | MANHATTAN TEXTILE & GARMENT CORP | 5,000 | $1.00 | $5,000.00 | $500.00 | $4,500.00 |
| 2 | SABRINA ( CAMBODIA GARMENT ) | 2,640 | $1.00 | $2,640.00 | $264.00 | $2,376.00 |
| 3 | SUPPREME CHOICE ( CAMBODIA) GARMENT | 4,100 | $0.80 | $3,280.00 | $328.00 | $2,952.00 |
| 4 | JOYFUL GARMENT CO.,LTD | 4,000 | $0.60 | $2,400.00 | $240.00 | $2,160.00 |
| 5 | SHINGTEX ( CAMBODIA) CO.,LTD | 3,300 | $0.60 | $1,980.00 | $198.00 | $1,782.00 |
| 6 | SUNTEX PTE.LTD | 2,100 | $0.60 | $1,260.00 | $126.00 | $1,134.00 |
| | | **21,140** | | **$16,560** | **$1,656** | **$14,904** |

ANNEX - A

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

10:02 AM, 09/18/2003

MINISTRY OF COMMERCE

TENDER of QUOTA

TENDER of QUOTA

September 18, 2003

| ID | COMPANY NAME | 638/639 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 198,135 | $0.80 | | | |
| 1 | M&V INTERNATIONAL MANUFACTURING | 525 | $1.00 | $525.00 | $52.50 | $472.50 |
| 2 | CAMBO FASHION CO.,LTD | 30,000 | $0.80 | $24,000.00 | $2,400.00 | $21,600.00 |
| 3 | EVRGREEN GARMENT | 800 | $0.80 | $640.00 | $64.00 | $576.00 |
| | | 31,325 | | $25,165.00 | $2,516.50 | $22,648.50 |

| ID | COMPANY NAME | 645/646 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 95,964 | $0.50 | | | |
| 1 | M&V INTERNATIONAL MANUFACTURING | 21 | $0.70 | $14.70 | $1.47 | $13.23 |
| | | 21 | | $14.70 | $1.47 | $13.23 |

| | TOTAL | TOTAL10% | TOTAL90% |
|---|---|---|---|
| Sub-TOTAL | $149,819.70 | $14,981.97 | $134,837.73 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ...៩២០.....អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ « តែ្បងមានជ័យ » ទៅជាវិទ្យាល័យ « ជា ស៊ីម តែ្បងមានជ័យ »
ស្ថិតនៅក្នុងឃុំកំពង់ប្រណាក ស្រុកតែ្បងមានជ័យ ខេត្តព្រះវិហារ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់នាយកវិទ្យាល័យតែ្បងមានជ័យ លេខ ៤១ វត ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រះវិហារ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ « តែ្បងមានជ័យ » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ជា ស៊ីម តែ្បងមានជ័យ » ស្ថិតនៅក្នុងឃុំកំពង់ប្រណាក ស្រុកតែ្បងមានជ័យ ខេត្តព្រះវិហារ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល :</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តព្រះវិហារ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៨៧១ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ វ៉ារិន

ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកវ៉ារិន លេខ ២០-០៣ អយកស្រ.វរ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « វ៉ារិន » ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប ចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ៣០ខែ កញ្ញា ឆ្នាំ ២០០៣

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តសៀមរាប" ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ-ឯកសារ ទា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៩៧៧ អយក.ប្រក

# ប្រ ក ា ស

ស្តីពីការបើកអនុវិទ្យាល័យ ចុងឃ្មៀស

ស្ថិតនៅក្នុងឃុំចុងឃ្មៀស ស្រុកសៀមរាប ខេត្តសៀមរាប

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកសៀមរាប លេខ ៧៣២ អយកស្រសរ.ភគស ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំ រេ ច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ចុងឃ្មៀស » ស្ថិតនៅក្នុងឃុំចុងឃ្មៀស ស្រុកសៀមរាប ខេត្តសៀមរាប ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។ ៚

ភ្នំពេញ , ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តសៀមរាប" ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ.....១៥៧.....ក.ធ.ស

## សេចក្តីសំរេច
## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- ពាក្យសុំកែសំរួលរចនាសម្ព័ន្ធដឹកនាំគណៈកម្មការសង្ឃសាសនាមហាយាន (វៀតណាម) ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៣
- ចំណារបញ្ជូនរបស់មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ លេខ៣៣៤ប.ជ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០៣

## សំរេច

**ប្រការ១:** ឯកភាពលើការតែងតាំងគណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) តាមការស្នើសុំដូចខាងក្រោមៈ

១-ព្រះអង្គ **ធិច ធៀនធុង** ប្រធានគណៈកម្មការសង្ឃ ទៅជាប្រធានកិត្តិយស

២-ព្រះអង្គ **ធី អាងឡាក់** ជាប្រធានគណៈកម្មការសង្ឃ

៣- ព្រះសង្ឃ **ធិច ធៀកហាន់** ជាអនុប្រធានទី១

៤-ព្រះសង្ឃ **ធិច ធាងហ៊ូ** ជាអនុប្រធានទី២

**ប្រការ២:** គណៈកម្មការសង្ឃសាសនាមហាយាន ( វៀតណាម ) ដែលបានជ្រើសតាំងទទួលស្គាល់នេះ ចាំបាច់ត្រូវធ្វើសេចក្តីរាយការណ៍ស្តីពីសកម្មភាពសាសនាមហាយាន ( វៀតណាម ) ទាំងអស់មក

ក្រសួងធម្មការ និងសាសនា ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវនិងទៀងទាត់រៀងរាល់ ត្រីមាស ឆមាស និងឆ្នាំ ។

**ប្រការ៣:** គណៈកម្មការសង្ឃសាសនាមហាយាន (វៀតណាម) ត្រូវមានកាតព្វកិច្ចគ្រប់គ្រងនិងដឹកនាំបរិស័ទ ដែលគោរពពុទ្ធសាសនា(មហាយាន) ក្នុងន័យទ្រទ្រង់និងលើកស្ទួយសាសនានេះឱ្យបានត្រឹមត្រូវតាមពុទ្ធឱវាទរបស់ពុទ្ធសាសនា(មហាយាន) បានល្អប្រពៃ ។

**ប្រការ៤:** គណៈកម្មការសង្ឃសាសនាមហាយាន (វៀតណាម) ត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំគណៈកម្មការសង្ឃសាសនាមហាយាន (វៀតណាម) ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័ន-អង្គភាព ដែលពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៥:** ទុកជាមោឃ សេចក្តីសំរេច លេខ ១១៣កធស ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់ក្រសួងធម្មការនិងសាសនា ស្តីពីឱ្យបង្កើតគណៈកម្មការសង្ឃសាសនាមហាយាន (វៀតណាម) ។

**ប្រការ៦:** រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៧:** នាយកដ្ឋានពាហិរសាសនា - នាយកដ្ឋានរដ្ឋបាល- ខុទ្ទកាល័យ-អគ្គនាយកដ្ឋានធម្មការ គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តនីសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៨:** សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ៧ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ជា-សាវឿន

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

"ដើម្បីគោរពជូនជ្រាប"

-រាជកិច្ច ដើម្បីចុះផ្សាយ

-សាលាក្រុងភ្នំពេញ

-មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ

" ដើម្បីមុខការ "

-ឯកសារ. កាលប្បវត្តិ